
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 2.12 **បញ្ញត្តិទាំងដប់ប្រការ**

ជាយូរលង់មកហើយ បុរសម្នាក់ឈ្មោះម៉ូសេ បានដឹកនាំរាស្ត្ររបស់ព្រះចេញពីស្រុកអេស៊ីព្ទ ។ ប្រជាជនហេព្រើរទាំងនេះ ត្រូវបានគេធ្វើបាបនៅស្រុកអេស៊ីព្ទ ហើយព្រះទ្រង់បានសន្យាថា នឹងនាំពួកគេទៅកាន់កន្លែងមួយផ្សេងទៀត ដើម្បីរស់នៅ។ ពួកគេបានហៅកន្លែងថ្មីនេះថា "ទឹកដីសន្យា" ។ មានបញ្ហាជាច្រើននៅតាមផ្លូវ។ ប្រជាជនចាប់ផ្តើមត្អូញត្អែរ ហើយសួរលោកម៉ូសេនូវសំណួរជាច្រើន អំពីរបៀបដែលព្រះនឹងថែរក្សាពួកគេ។ លោកម៉ូសេបានព្យាយាមឆ្លើយតាម ដែលគាត់អាចឆ្លើយទៅបាន ។ ទោះជាយ៉ាងណាក៏ដោយ ពេលខ្លះគាត់ខឹងនឹងពួកគេមែន ប៉ុន្តែព្រះនៅតែនៅជាមួយពួកគេជានិច្ច ទោះបីពួកគេសុខ ឬទុក្ខយ៉ាងណាក៏ដោយ ។ ព្រះទ្រង់មិនដែលឲ្យពួកគេបរាជ័យទេ។ ថ្ងៃមួយលោកម៉ូសេបានឡើងទៅជួបព្រះ ។ ព្រះអម្ចាស់ត្រាស់ហៅគាត់ ឲ្យឡើងទៅលើភ្នំមួយហៅថា ភ្នំស៊ីណាយ។ នៅពេលដែលលោកម៉ូសេទៅដល់ទីនោះ ព្រះបានមានបន្ទូលថា ទ្រង់មានច្បាប់មួយចំនួនសម្រាប់ប្រជាជន។ ប្រសិនបើពួកគេនឹងស្តាប់ ហើយគោរពតាមច្បាប់ទាំងនេះ ដែលព្រះមានសម្រាប់ពួកគេ ពួកគេនឹងក្លាយជាមនុស្សពិសេសណាស់។ ក្នុងចំណោមប្រជាជនទាំងអស់នៅលើផែនដី ពួកគេគឺជាមនុស្សដែលព្រះបានជ្រើសរើសតាំង ។ លោកម៉ូសេត្រឡប់ទៅប្រាប់ប្រជាជនវិញ។ ពួកគេទាំងអស់បានយល់ព្រម ។ ពួកគេឆ្លើយថា៖ «អ្វីៗទាំងអស់ដែលព្រះបង្គាប់យើងឲ្យធ្វើ យើងនឹងធ្វើ»។ ប្រជាជនត្រូវសម្អាតខ្លួន និងសម្អាតសម្លៀកបំពាក់ ។ នៅថ្ងៃទីបី ព្រះអម្ចាស់នឹងយាងចុះមកលើភ្នំស៊ីណាយ នៅចំពោះមុខប្រជាជនទាំងមូល ។ ពួកគេត្រូវរង់ចាំលោកម៉ូសេនៅពេលគាត់ចូលទៅជិតព្រះនៅលើភ្នំ ។ មានព្រំដែនព័ទ្ធជុំវិញភ្នំ ដូច្នេះប្រជាជន មិនអាចទៅតាមលោកម៉ូសេបានទេ ។ ព្រោះព្រះបរិសុទ្ធណាស់ ។ ប្រសិនបើអ្នកណាព្យាយាមឡើងលើភ្នំ ក្រៅពីលោកម៉ូសេនោះ ពួកគេនឹងត្រូវស្លាប់។ មានផ្សែងនៅលើភ្នំ ដូច្នេះលោកម៉ូសេ មិនបានឃើញព្រះភ័ក្ររបស់ព្រះជាម្ចាស់ទេ ។ គាត់បាន គ្រាន់តែឮទ្រង់ប៉ុណ្ណោះ ។

ព្រះបានប្រទានបទបញ្ញត្តិទាំង១០ប្រការនេះ សម្រាប់ប្រជាជន៖

១) កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ ។

២) កុំឲ្យឆ្លាក់ធ្វើ ឬក្រាបថ្វាយបង្គំចំពោះរូបណាឡើយ ។

៣) កុំឲ្យចេញព្រះនាមព្រះយេហូវ៉ាជាអាសារឥតការឡើយ។

៤) ចូរនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាថ្ងៃបរិសុទ្ធ។

៥) ចូរគោរពប្រតិបត្តិមាតាបិតា ។

៦) កុំឲ្យសម្លាប់មនុស្សឲ្យសោះ ។

៧) កុំឲ្យផិតក្បត់ឲ្យសោះ។

៨) កុំឲ្យលួចប្លន់ឲ្យសោះ ។

៩) កុំឲ្យធ្វើជាទីបន្ទាល់ក្លែងឲ្យសោះ ។

១០) កុំឲ្យលោភឲ្យសោះ ។

ព្រះទ្រង់បានឆ្លាក់ច្បាប់ទាំងនេះនៅលើបន្ទះថ្មមួយ ហើយលោកម៉ូសេបានយកវាចុះពីលើភ្នំទៅចំពោះមនុស្សគ្រប់ជាតិសាសន៍ ។ (**និក្ខមនំ ២០**

## 2.12 បញ្ញត្តិទាំងដប់ប្រការ - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

**កំណត់សម្គាល់**

1) ប្រជាជនអ៊ីស្រាអែលបានធ្វើដំណើរនៅតាមផ្លូវមួយ ។ លោកម៉ូសេបាននាំពួកគេទៅកន្លែងថ្មីមួយដើម្បីរស់នៅ ។ វាគឺជាដំណើរដ៏វែងឆ្ងាយមួយ ។ មនុស្សគ្រប់គ្នាត្រូវនៅជុំគ្នា ។ ពេលខ្លះវាពិតជាពិបាក ។ ព្រោះមានមនុស្សច្រើនណាស់ ។ ពេលខ្លះពួកគេបានខឹង ។ ទោះជាយ៉ាងណាក៏ដោយ ព្រះទ្រង់ជ្រាបរួចទៅហើយ ហើយតែងតែគង់នៅជាមួយពួកគេជានិច្ច ។

2) ព្រះទ្រង់ចង់មានបន្ទូល ទៅកាន់លោកម៉ូសេនៅលើភ្នំមួយ ។ ទ្រង់មានអ្វីដែលត្រូវប្រាប់ទៅកាន់ប្រជាជនទាំងនោះ ។ ទ្រង់ចង់ឲ្យពួកគេក្លាយជាមនុស្ស ដែលព្រះអង្គបានជ្រើសរើស ។ ពួកគេនឹងក្លាយជាមនុស្សពិសេសទៅចំពោះព្រះ ។ ពួកគេបាននិយាយថា ពួកគេនឹងធ្វើអ្វីទាំងអស់ដែលទ្រង់បានប្រាប់ដល់ពួកគេ ។

3) នៅពេលដែលលោកម៉ូសេឡើងទៅលើភ្នំម្តងទៀត ប្រជាជនត្រូវបានព្រមានថា មិនឲ្យដើរតាមគាត់ ឬព្យាយាមរកមើលព្រះជាដាច់ខាត ។ ព្រោះព្រះអម្ចាស់ទ្រង់បរិសុទ្ធណាស់ ។ ប្រសិនបើពួកគេព្យាយាមធ្វើរឿងទាំងនោះ ពួកគេនឹងត្រូវស្លាប់ ។

4) ព្រះទ្រង់មិនបានទាំងឲ្យលោកម៉ូសេឃើញទ្រង់ផង ។ ទ្រង់បានឲ្យលោកម៉ូសេនូវច្បាប់ចំនួន១០ប្រការ (ហៅថាបញ្ញត្តិទាំង១០) ដើម្បីបង្ហាញប្រជាជនអំពីរបៀបរស់នៅ ។

**សំណួរ:**

1) ហេតុអ្វីបានជាប្រជាជនចាកចេញពីស្រុកអេស៊ីព្ទ?

2) តើបុរសនោះឈ្មោះអ្វី ដែលនាំពួកគេទៅកាន់ទឹកដីថ្មី?

3) តើលោកម៉ូសេត្រូវទៅណាដើម្បីឲ្យព្រះទ្រង់មានបន្ទូលទៅកាន់គាត់?

4) តើព្រះទ្រង់បានប្រទានឲ្យលោកម៉ូសេនូវបញ្ញត្តិប៉ុន្មានប្រការ ដើម្បីឲ្យដល់ប្រជាជន?

5) តើព្រះទ្រង់នឹងធ្វើអ្វី ប្រសិនបើប្រជាជនគោរពតាមបញ្ញត្តិទាំងនោះ?

**ចម្លើយ:**

1) ពួកគេបានធ្វើដំណើរទៅកាន់ទឹកដីថ្មីដែលព្រះបានសន្យា ។

2) បុរសនោះឈ្មោះម៉ូសេ ។

3) ម៉ូសេត្រូវឡើងទៅលើភ្នំ ។

4) ព្រះទ្រង់បានប្រទានច្បាប់ឲ្យលោកម៉ូសេដល់ទៅ១០ប្រការ ។

5) ព្រះទ្រង់នឹងធ្វើឱ្យពួកគេក្លាយជាមនុស្សពិសេសរបស់ទ្រង់ ។



Kids of Destiny®
Reaching the Next Generation

www.kidsofdestiny.org